# រឿង មហាចោរនៅទល់ដែន

**ភាគទី៣៩ (ទារុណកម្ម)**

ឱ! ទារុណកម្មដែលមានន្ទទទួល ស្ត្រីឃើញហួសសេចក្តីស្មានរបស់នាងទៅហើយ។ ឥឡូវមានហេតុមួយទៀត ដែលបន្ថែមទម្ងន់ទៅលើអ្នករងគ្រោះ។ ក្នុងមនោចិត្តរបស់យុវតីដែលអាក្រក់ ចំពោះមានន្ទឥតឧបមានេះមានបន្ទះល្អមួយដែរ។ ស្រីដើរយ៉ាងលឿនទៅចាប់រំពាត់ពីដៃកាមា បេះគ្រវាត់ចោលចេញដូចដែលនាងបានធ្វើនៅក្នុងគុក។ កល្យាណទៅដងទឹកហុចឲ្យមានន្ទដែលមានទឹកមុខមាំ យកទឹកនោះទៅឲ្យអ្នកស្រេកឃ្លាន។

ធីតាខ្សឹបដាក់ត្រចៀកកាមាថា:

ទៅ! បងទៅចុះ! មេទ័ពមិនត្រូវវាយអ្នកទោសនឹងដៃឯងនោះទេនាំឲ្យបងថោកទាបវិញទេ។ នាងដឹកដៃកាមាចេញដូចក្មេងម្នាក់ ដែលដឹកខ្លាកំណាចចេញពីកន្ទ្រងមួយ។ លុះមកដល់ក្នុងបន្ទប់នាងវិញ កល្យាណណែនណាន់តាន់តាប់ពេញដើមទ្រូង។

ធីតាយំ...ឱ! នាងយំអាណិតប្រុសដែលឥតដឹងខ្លួនថា ទទួលលំពែងទុក្ខរបស់នាង។ នាងយំៗឲ្យអស់ចិត្ត។ កញ្ញាហាក់ឮសំឡេងមួយស្រែកថា:

យំទៅមណី យំកុំឈប់។ ហែលក្នុងទឹកភ្នែកឯងចុះ។ នេះគឺកម្មដែលឯងធ្វើតែខ្លួនឯង។ លាងវេរាដែលឯងផ្តុំមកនោះទេ។ ទឹកភ្នែកឯងមានរសជាតិល្វីងណាស់ មិនសមហូរចេញពីភ្នែកឯងដែលស្អាតនោះទេ។ ឯងជាស្រីធន្ទាខ្លាំងណាស់។ គេល្អគ្រប់បែបយ៉ាង ឯងឈ្នានីសគេ។ ឯងយកល្បែងចិត្តមកសងសឹកគេ ដោយបន្ទំថា ជាល្បែងស្រុកទេសទៅវិញ។ មណី! បើអញវិញខ្មាសខ្លួនឯងស្លាប់ហើយ។

នោះហើយសំលេងសម្បជញ្ញៈ។ នេះហើយភ្នែករបស់សតិដែលជាអាទិទេពរបស់មនុស្សម្នាក់។ សំលេងនេះឮស្ងួរខ្សឹរៗខ្លាំងៗ ដែលអ្នកផងមិនឮរួចដែលមានតែមនុស្សដែលបានប្រព្រឹត្តខុស មានបទឧក្រិដ្ឋជាដើមនោះទើបឮ។

អត្ថបទដោយ៖ មាស សុភាព

សំឡេងនេះគ្រប់ដណ្ដប់រាងកាយយើង និងស្ងួនបេះដូងយើងធ្វើឲ្យយើងដកដង្ហើមមិនបានស្រួល មើលមុខគេឯទៀតមិនបាន ចង់គេចខ្លួនទៅឯណាឆ្ងាយៗឲ្យបាត់ពីមុខយើងទៅ។ តើធន្ទាមណីទៅឯណាឲ្យផុតពីភ្នែកសម្បជញ្ញៈនេះ? ទេ! ទោះទៅដល់ទីណាក៏ភ្នែកនេះតាមមើលក្រឡោត សំឡេងនេះតាមនិយាយប្រដៅកិនបន្ទោសដរាប។

ឱ! នាងមណីនឹងឃើញដំណាក់ឪពុកនាង ដែលនៅនាខេត្តសុរិន្ទ្រសីមា។ នាងត្រូវតែទៅៗ ឲ្យបានឆ្ងាយបន្តិចពីមុខប្រុសជាគូរកម្ម ទៅឲ្យភ្លេចរឿងចាស់ចេញទៅរកទីមួយដើម្បីសង្រ្វេងសង្រ្វែតែម្នាក់ឯង។

ព្រឹកឡើង កែវមណីឡើងទៅសំពះព្រះកម្ពុតជាឪពុកមា ធ្វើដំណើរត្រឡប់ទៅផ្ទះវិញ។ ព្រះកម្ពុត និងកាមាឃាត់ស្រីយ៉ាងណា ក៏នាងចេះតែរកពាក្យដោះសារ និងធ្វើដំណើរនេះ។ នៅចុងបង្អស់ នាងបានអនុញ្ញាតទៅតាមសេចក្ដីស្នើមែន ក្នុងរយៈវេលាបីថ្ងៃទៀត។

(សូមរង់ចាំតាមដានភាគទី៤០ នៅសប្ដាហ៍ក្រោយ)

អត្ថបទដោយ៖ មាស សុភាព